**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រុមប្រឹក្សាធម្មនុញ្ញ**

**សំណុំរឿង**

លេខ : ០៦៨/០១២/២០០៣

ចុះថ្ងៃទី ០២ ខែ កក្កដា ឆ្នាំ២០០៣

**សេចក្តីសម្រេច**

លេខ : ០៥៣/០០៤/២០០៣ កបធ.ច

ចុះថ្ងៃទី ១១ ខែ កក្កដា ឆ្នាំ២០០៣

# ក្រុមប្រឹក្សាធម្មនុញ្ញ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ជស/រកម/០៤៩៨/០៦ ចុះថ្ងៃទី ០៨ ខែ មេសា ឆ្នាំ១៩៩៨ ប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៩០២/០១៧ ចុះថ្ងៃទី ១៧ ខែ កញ្ញា ឆ្នាំ២០០២ ប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ
- បានឃើញលិខិតលេខ ៣៩០ រស ចុះថ្ងៃទី ៣០ ខែ មិថុនា ឆ្នាំ២០០៣ របស់ប្រធានរដ្ឋសភា ស្នើឱ្យក្រុម-ប្រឹក្សាធម្មនុញ្ញបំភ្លឺចំពោះបណ្តឹងលេខ ១៨២/០៣ គ.ប.ស.យ ចុះថ្ងៃទី ២៥ ខែ មិថុនា ឆ្នាំ២០០៣ របស់លោក **គល់ បញ្ញា** នាយកប្រតិបត្តិនៃគណៈកម្មាធិការដើម្បីការបោះឆ្នោតដោយសេរី និង យុត្តិធម៌នៅកម្ពុជា ហើយដែលអគ្គលេខាធិការដ្ឋាននៃក្រុមប្រឹក្សាធម្មនុញ្ញទទួលបាននៅថ្ងៃទី ០១ ខែ កក្កដា ឆ្នាំ ២០០៣

**ក្រោយពីបានស្តាប់របាយការណ៍របស់សមាជិករាយការណ៍**

**ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់**

- យល់ឃើញថា ការសុំរបស់ប្រធានរដ្ឋសភាក្នុងលិខិតលេខ ៣៩០ រស ចុះថ្ងៃទី ៣០ ខែ មិថុនា ឆ្នាំ២០០៣

ឱ្យបំភ្លឺចំពោះសំណើរបស់លោក **គល់ បញ្ញា** លេខ ១៨២/០៣ គ.ប.ស.យ ចុះថ្ងៃទី ២៥ ខែ មិថុនា ឆ្នាំ ២០០៣ សុំឱ្យបកស្រាយមាត្រា ១៣៧ ថ្មី វាក្យខ័ណ្ឌទី១ និង ទី២ នៃព្រះរាជក្រម លេខ នស/រកម/ ០៩០២/០១៧ ចុះថ្ងៃទី ១៧ ខែ កញ្ញា ឆ្នាំ២០០២ អាចយកមកពិនិត្យបាន ដោយអនុលោមតាមមាត្រា ១៤១ ថ្មី វាក្យខ័ណ្ឌទី២ នៃរដ្ឋធម្មនុញ្ញ និង មាត្រា ១៨ នៃព្រះរាជក្រមលេខ ជស/រកម/០៤៩៨/០៦ ចុះថ្ងៃទី ០៨ ខែ មេសា ឆ្នាំ១៩៩៨

- យល់ឃើញថា វាក្យខ័ណ្ឌទី១ នៃមាត្រា ១៣៧ ថ្មី នៃព្រះរាជក្រមលេខ នស/០៩០២/០១៧ ចុះថ្ងៃទី១៧ ខែ កញ្ញា ឆ្នាំ២០០២ នេះ សំដៅទៅលើទីកន្លែងនៃការរាប់សន្លឹកឆ្នោតដែលត្រូវធ្វើជាគោលការណ៍ នៅទីស្នាក់ការគណៈកម្មាធិការឃុំ សង្កាត់រៀបចំការបោះឆ្នោត ប៉ុន្តែក្នុងករណីចាំបាច់ គណៈកម្មាធិការជាតិ-រៀបចំការបោះឆ្នោតមានសិទ្ធិកំណត់យកទីកន្លែងសុវត្ថិភាពណាមួយក៏បាន
- យល់ឃើញថា វាក្យខ័ណ្ឌទី២ នៃមាត្រា ១៣៧ ថ្មី ដដែលនេះ មិនមានលំអិតឱ្យច្បាស់លាស់អំពីនីតិវិធីនៃការដឹកជញ្ជូនហិបឆ្នោត ឬ ការរាប់សន្លឹកឆ្នោតទេ ដោយទុកភារកិច្ចនេះជូនគណៈកម្មាធិការជាតិរៀបចំ-ការបោះឆ្នោត ( គ.ជ.ប ) ក្នុងស្មារតីចង់ឱ្យ គ.ជ.ប មានលទ្ធភាពគ្រប់គ្រាន់ក្នុងការរិះរកប្រតិបត្តិភាព ( ភាពដែលអាចប្រតិបត្តិបាន ) ដែលត្រូវឆ្លើយនឹងល័ក្ខខ័ណ្ឌតម្លាភាព សុវត្ថិភាព គ្មានការគំរាមគំហែង គ្មានការបំភិតបំភ័យ លក្ខណៈសេរី ត្រឹមត្រូវ និង យុត្តិធម៌ ដែលច្បាប់បានបញ្ញត្តិនោះ ។

  ដូច្នេះ ជាស្មារតីច្បាប់ ក៏ពុំមានត្រង់ណាដែលបង្ហាញឱ្យឃើញថា ចង់ឱ្យមានការចាក់បញ្ចូលសន្លឹកឆ្នោតតាមរបៀបណាមួយជាក់ច្បាស់នោះឡើយ
- យល់ឃើញថា ការសម្ងាត់របស់អ្នកបោះឆ្នោតក្នុងការបោះឆ្នោត ជាគោលការណ៍ សម្រាប់ការពារសិទ្ធិផ្ទាល់ខ្លួនបុគ្គលអ្នកបោះឆ្នោត និង សន្តិសុខសុវត្ថិភាពរបស់គេ ។ គោលការណ៍នេះ ក្នុងពេលបច្ចុប្បន្នពុំអាចមានវិសាលភាពដល់ភូមិករ និង សហគមន៍ភូមិសាស្ត្រឡើយ ទោះបីក្នុងករណីណាក៏ដោយ ។ នៅក្នុងច្បាប់បោះឆ្នោតជាធរមាន ពុំទាន់មានគោលការណ៍ដើម្បីការពារការសម្ងាត់អ្នកបោះឆ្នោតជាសមូហភាពតាមសហគមន៍ភូមិសាស្ត្រនៅឡើយទេ ។

## សម្រេច

**មាត្រា ១** : វាក្យខ័ណ្ឌទី១ និង ទី២ នៃមាត្រា ១៣៧ ថ្មី នៃព្រះរាជក្រមលេខ នស/រកម/០៩០២/០១៧ ចុះថ្ងៃទី ១៧ ខែ កញ្ញា ឆ្នាំ២០០២ ប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ត្រូវបកស្រាយដូចមានចែងក្នុងមូលបទខាងលើ ។

**មាត្រា ២** : សេចក្តីសម្រេចនេះធ្វើនៅរាជធានីភ្នំពេញថ្ងៃទី ១១ ខែ កក្កដា ឆ្នាំ២០០៣ នាសម័យប្រជុំពេញអង្គនៃ

ក្រុមប្រឹក្សាធម្មនុញ្ញ ជាសេចក្តីសម្រេចស្ថាពរ បិទផ្លូវតវ៉ា ហើយមានអានុភាពអនុវត្តទៅលើអំណាចទាំងអស់ដែលមានចែងក្នុងរដ្ឋធម្មនុញ្ញ និង ត្រូវចុះផ្សាយក្នុងរាជកិច្ច ។

រាជធានីភ្នំពេញ ថ្ងៃទី ១១ ខែ កក្កដា ឆ្នាំ២០០៣

**ជ.ក្រុមប្រឹក្សាធម្មនុញ្ញ**

**ប្រធាន**

**ហត្ថលេខា និង ត្រា**

**ប៊ិន ឈិន**